ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦៣៤ .សហវ. [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០១១

**<u>គោរពជូន</u>**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ លោក លោកស្រី**
**ជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និង ប្រធានអង្គភាព**
**ក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន**

**<u>កម្មវត្ថុ</u> : ផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣**

**<u>យោង</u>** :- ព្រះរាជក្រមលេខ នស / រកម / ០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- ព្រះរាជក្រមលេខ នស / រកម / ១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០១១
- អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤០ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ ១៣៤ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ប្រកាសលេខ ៤០៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារក្រមសីលធមិសំរាប់សវនករផ្ទៃក្នុង និងស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង
- ប្រកាសលេខ ១១០៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពនានា ក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជ្រាបថា ក្នុងគោលបំណងបន្តបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលការងារនៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ក្រោយពីទទួលបាននូវសមិទ្ធកម្ម និងការផ្លាស់ប្តូរថ្មីៗនៅផ្ទៃក្នុងក្រសួង ក៏ដូចជាផ្ទៃក្នុងរាជរដ្ឋាភិបាល ពិសេសនៅការក្នុងការងារកែទំរង់ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ ដូចជាៈ ភាពកាន់តែជឿទុកចិត្តរបស់ថវិកា និងការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលគ្រប់អង្គភាពកំពុងតែប្រយុទ្ធដណ្តើមជោគជ័យនាពេលបច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជំរុញឱ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការកែលំអនូវផែនការសវនកម្មឱ្យកាន់តែមានលក្ខណៈស្តង់ដារអន្តរជាតិ សំដៅលើកកំពស់គុណភាពការងារ សវនកម្មឱ្យធានាបាននូវអនុសាសន៍ល្អៗ ដើម្បីរួមចំណែកសំរេចបាននូវកិច្ចការកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ " **ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** " ហើយឈានចូលទៅដំណាក់កាលទី ៣ ជាបន្តទៀត ។

ក្នុងគោលដៅនេះ ផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣ ត្រូវបានរៀបចំឡើងដោយប្រើ "អភិក្រមផ្តោតលើកិច្ចដំណើរការមានហានិភ័យ" (Risk Based Process Focused Approach) បូកបញ្ចូលនូវកត្តាចំបងៗខាងក្រៅ ដូចជាបច្ច័យពីការវិវត្តន៍នៃការងារកែទំរង់ជារួម និងទាំងអាទិភាពថ្មីៗរបស់រាជរដ្ឋាភិបាលផងដែរ ។ លទ្ធផលវាយតំលៃហានិភ័យ និងប្រតិបត្តិការទាំងឡាយរបស់ក្រសួង ត្រូវបានសន្មតថានឹងមិនមានការផ្លាស់ប្តូរនៅក្នុងកំឡុងពេលនៃផែនការទេ ។ ក្រៅពីនេះ ខ្ញុំក៏បានណែនាំឱ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុង យកចិត្តទុកដាក់បន្ថែមលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០១១ វិន័យទាំង ១១" ៥" បច្ច័យដោយឡែកៗពីលទ្ធផលនៃកំណែទំរង់នៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ព្រមទាំងពេលវេលា បទពិសោធន៍ និងសមត្ថភាព លទ្ធភាពរបស់នាយកដ្ឋានសវនកម្មផ្ទាល់ ដែលទទួលបានក្នុងអំឡុងពេល ៦ ឆ្នាំកន្លងមកនេះ ដោយលៃយ៉ាងណាធ្វើឱ្យផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣ ក្លាយជាផែនការសវនកម្មខិតទៅរកក៏រិតស្តង់ដារអន្តរជាតិ តែមានភាពជាក់ស្តែងអាចគោរព និងអនុវត្តបាន និងបំរើដល់គោលបំណងដូចបានរំលឹកខាងលើ ។

ផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងរំកិលបីឆ្នាំ ២០១១-២០១៣ ត្រូវបានរៀបចំឡើងឱ្យគ្របដណ្តប់លើគ្រប់អង្គភាពទាំងអស់ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន ។ វិសាលភាពសវនកម្មនៃផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល ត្រូវបានរំលេចទៅតាមក៏រិតនៃកិច្ចដំណើរការ មានៈ មេហ្គាដំណើរការ ដំណើរការចំបង និង អនុដំណើរការ ដូចមានក្នុងតារាងឧបសម្ព័ន្ធ "**ក**" ។ ផែនការនេះក៏អាចមានលក្ខណៈទន់ភ្លន់ក្នុងករណីចាំបាច់ ។

ចំនួនសវនកម្មសំរាប់គោលដៅនីមួយៗក្នុងរយៈពេលបីឆ្នាំ ត្រូវបានកំណត់តាមរយៈការធ្វើអាទិភាវូនីយកម្ម លើកំរិតហានិភ័យនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និងសាខាទាំងនោះ ។ វិសាលភាពសវនកម្មដែលត្រូវកំណត់យកមកធ្វើសវនកម្មតាមឆ្នាំនីមួយៗ បានរៀបចំនៅក្នុងតារាងឧបសម្ព័ន្ធ " **ខ** " ដែលវិសាលភាពសវនកម្មក្នុងឆ្នាំទី ១ ត្រូវបំរើជាវិសាលភាពសវនកម្មសំរាប់ផែនការសវនកម្មប្រចាំឆ្នាំ ២០១១ ។ ក្រៅពីនេះ ក៏អាចមានការធ្វើសវនកម្មដោយឡែក នៅពេលមានការប្ដឹងផ្ដល់ឬការចាំបាច់ជាយថាហេតុផងដែរ ។ អនុសាសន៍ដែលបានផ្ដល់ជូននឹងត្រូវត្រួតពិនិត្យឡើងវិញ ក្នុងរយៈពេលមួយកំណត់មិនលើសពី ៦ ខែ ក្រោយ ។

ផែនការយុទ្ធសាស្ត្រសវនកម្មនឹងត្រូវត្រួតពិនិត្យឡើងវិញយ៉ាងហោចមួយឆ្នាំម្ដង ដើម្បីកែតំរូវយោងទៅតាមលទ្ធផលថ្មីនៃការវាយតម្លៃហានិភ័យសវនកម្ម ដែលបានរងឥទ្ធិពលពីការផ្លាស់ប្ដូរបរិស្ថានសវនកម្មសំខាន់ៗ ពិសេស អាទិភាពនៃ ***កសហវ*** ឬការរកឃើញថ្មីៗ ។ បំលាស់ប្ដូរថ្មីៗទាំងនេះ នឹងត្រូវកត់សំគាល់នៅក្នុងផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល ដែលបានកែលំអ និងដាក់ជូនរដ្ឋមន្ត្រីពិនិត្យនិងសំរេច ។ សូមភ្ជាប់មកជាមួយនូវផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល តារាងឧបសម្ព័ន្ធ " ក " និង " ខ " ចំនួន ០១ ច្បាប់ ។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តមប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រីជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣ នេះ ឱ្យបានសំរេចជោគជ័យជាមួយប្រសិទ្ធភាពខ្ពស់ ។៥/

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**
-អាជ្ញាធរសវនកម្មជាតិ
-សាលារាជធានីភ្នំពេញ និងសាលាខេត្ត
-គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព
នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ